00363511

001/18-07-2007-ECCC/TC
E1/32

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 08 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរ
## នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"

សាធារណៈ

## សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

## ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ -ថ្ងៃជំនុំជម្រះទី ២០

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 18/08/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Fuy

រៀបចំដោយ: ឌុច ផារី និង Natacha WEXELS-RISER

---

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Crippa Matteo,លោកស្រី សែ កុលវុឌ្ឍី,កញ្ញា Natacha Wexels-Riser លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក យ៉េត ចរិយា លោក William Smith លោក ពេជ្រ សម្បត្តិ លោក Zachery Lampell លោក ប៉ាក់ ចន្ទលីណូ |

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

| |
|---|
| ជនជាប់ចោទ៖ លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ លោក François Roux លោកស្រី Heleyn Unac លោក ចាន់ រ៉ាវុធ លោកស្រី Marie-Paule Canizares លោកស្រី Lucile NATTIEZ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក ខូវ កែវរតនៈ លោក សាន រាដា លោក អ៊ុច អារុន |
| ផ្សេងៗ៖ |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃ | ចាប់ផ្តើមម៉ោង៖ ៩.១៥ | បញ្ចប់ម៉ោង៖ ១៦.២៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាក | ចាប់ផ្តើមម៉ោង៖១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖១៤.៥០ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង ៤៥ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការប្រកាសសេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ | អង្គជំនុំជម្រះ | ៩.១៥ | ៩.២១ |
| ការជូនដំណឹងពីលទ្ធផលនៃកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើនៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩ | អង្គជំនុំជម្រះ | ៩.២២ | ៩.២៩ |
| ការតាំងសំនួរដល់ជនជាប់ចោទទាក់ទងនិងប្រតិបត្តិការ ស ២១ | អង្គជំនុំជម្រះ | ៩.៣០ | ១៦.២៥ |
| ការទទួលយកសំណើររបស់លោកមេធាវី Pierre Olivier Sur ដែលសុំឲ្យជំនួយការរបស់គាត់ Jessica | អង្គជំនុំជម្រះ | ១៥.៣០ | ១៥.៣០ |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃនីតិវិធី- ១៥ មិថុនា ២០០៩ /សាធារណៈ

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

| | | | |
|---|---|---|---|
| Finelle បានចូលរួមសវនការ | | | |
| | | | |

<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>

**ការប្រកាសនូវផ្នែកនៃសេចក្តីសម្រេចលើសំណើរសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ**

- អង្គជំនុំជម្រះប្រកាសនូវផ្នែកនៃសេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ និងបានចង្អុលបង្ហាញថា ឯកសារដែលជាសេចក្តីសម្រេចទាំងស្រុងគឺមាននៅលើគេហទំព័ររបស់ អ វ ត ក ។

**ការជូនដំណឹងពីលទ្ធផលនៃកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើនៅថ្ងៃ ទី ១១ ខែ មិថុនា ឆ្នាំ ២០០៩**

បន្ថែមលើកិច្ចប្រជុំរៀបចំសវនាការមួយ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូង សូមជូនដំណឹងដល់សាធារណជននិងភាគីពាក់ព័ន្ធទាំងអស់ អំពីនីតិវិធីដែលធ្វើដូចខាងក្រោមនេះ

ដំបូង អង្គជំនុំជម្រះសាលសដំបូង បានកត់ត្រាយ៉ាងយកចិត្តទុកដាក់ នូវរាល់ការលើកឡើងរបស់ភាគីទាំងអស់ ទាក់ទងនឹងការកំណត់ថេរវេលានៃការបញ្ចប់ការពិភាក្សាដេញដោលបង្ហាញភស្តុតាងលើសំណុំរឿងលេខ០០១ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ ជាពិសេស អង្គជំនុំជម្រះក៏បានកត់សម្គាល់ឃើញថា ភាគីនានាបានលើកឡើងជាគំនិតថា ការពិភាក្សាដេញដោលក្នុងការបង្ហាញភស្តុតាង អាចនឹងបានបញ្ចប់ នៅរវាងខែសីហា និងខែធ្នូ ឆ្នាំ២០០៩ ។ ដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូងកំពុងធ្វើការពិនិត្យនូវកាលវិភាគសវនាការ និងលទ្ធភាពធ្វើយ៉ាងណា ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ ដើម្បីជាប្រយោជន៍ដល់ការជំនុំជម្រះ ដែលថាអាចនឹងបញ្ចប់បានឆាប់ ដោយរក្សាបាននូវកិច្ចដំណើរការនីតិវិធីមួយប្រកបដោយភាពយុត្តិធម៌ ។ ដោយហេតុថា នៅដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូង មិនទាន់អាចកំណត់បាននូវកាលបរិច្ឆេទជាក់លាក់ ពីរយៈពេលបញ្ចប់នីតិវិធីនៃការ[illegible]

និងបង្ហាញភស្តុតាងនោះឡើយ ។ អង្គជំនុំជម្រះ នឹងធ្វើការកំណត់នូវការបែងចែកម៉ោង និងពេលវេលា សម្រាប់និយាយដល់ភាគីពាក់ព័ន្ធនានា ។ អង្គជំនុំជម្រះសាលាដំបូង នឹងធ្វើការកំណត់នូវថេរៈវេលាសមស្របមួយ សម្រាប់ភាគីក្នុងការសួរដេញដោលដល់សាក្សីនីមួយៗ ។ អង្គជំនុំជម្រះសាលាដំបូង នឹងធ្វើការកំណត់ទៅតាមករណីនីមួយៗ នូវថេរៈវេលាសមស្រប សម្រាប់ភាគីក្នុងការសួរដេញដោលដល់សាក្សីនីមួយៗ ។

អង្គជំនុំជម្រះសូមជូនជាគំនិត ដែលខ្លួនគិតថា ជាទូទៅ គឺសមស្របសម្រាប់ភាគីត្រៀមខ្លួន ក្នុងការតាំងសំណួរដល់សាក្សី និងការធ្វើសេចក្តីសន្និដ្ឋាន ដូចតទៅ៖

ដំបូង ការតាំងសំណួរដល់សាក្សី ជាទូទៅ គឺពេលវេលា៣០នាទី សម្រាប់ការិយាល័យសហព្រះរាជអាជ្ញា ។ ៤០ នាទី សម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ គឺទាំងបួនក្រុម និង ៤០ នាទី សម្រាប់ក្រុមមេធាវីការពារក្តី ។

ទីពីរ ការធ្វើសេចក្តីសន្និដ្ឋាន អង្គជំនុំជម្រះនឹងអនុញ្ញាតពេលវេលាពី៥ ទៅ១០ នាទី សម្រាប់ការតាំងសំណួរ និងសម្រាប់ធ្វើការបដិសេធ និង ៥នាទីទៀតសម្រាប់ធ្វើការឆ្លើយតប ។ ជាវិធានទូទៅ ថេរៈវេលាដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង មិនអាចជាកម្មវត្ថុនៃការជជែកតវ៉ាដល់ភាគី ដែលនាំឲ្យអូសបន្លាយដល់ពេលវេលានោះឡើយ ។ ការកំណត់ពេលវេលា ៤០ នាទី សម្រាប់មេធាវីទាំងអស់ហ្នឹង គឺសម្រាប់ទាំងបួនក្រុម យកទៅធ្វើការបែងចែកគ្នា ។ ហើយអង្គជំនុំជម្រះដំបូង សូមផ្តល់ជាយោបល់ថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម អាចធ្វើការជ្រើសតាំងតាមលក្ខណៈវិលជុំ នូវមេធាវីខ្មែរម្នាក់ និងមេធាវីបរទេសម្នាក់ តំណាងឲ្យមេធាវីទាំងបួនក្រុម ក្នុងការតាំងសំណួរដល់សាក្សីនីមួយៗ ។ ក៏ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង សូមសង្កត់បញ្ជាក់ថា នេះគឺគ្រាន់តែជាយោបល់របស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ សម្រាប់ការបែងចែកពេលវេលា ៤០ នាទីនេះ ។ អង្គជំនុំជម្រះសាលាដំបូង នឹងធ្វើការផ្លាស់ប្តូរចំនួនថ្ងៃជំនុំជម្រះរបស់ខ្លួន ក្នុងគោលបំណងដើម្បីឲ្យមានពេលវេលាបន្ថែមមួយថ្ងៃទៀតក្នុងមួយខែ ។

នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះចង់ធ្វើការពន្យល់ដល់សាធារណជន និងភាគី



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

បញ្ជាក់ថា កិច្ចការភាគច្រើនរបស់អង្គជំនុំជម្រះ គឺធ្វើឡើងនៅក្រៅបន្ទប់សវនាការ រួមបញ្ចូលទាំងការរៀបចំសវនាការ ការពិភាក្សាលើបញ្ហាដែលស្នើឡើងដោយភាគី ការធ្វើសេចក្តីព្រាងលើសេចក្តីសម្រេចនានា និងការបកប្រែភាសា។ល។ កិច្ចការអស់ទាំងនេះ គឺមិនអាចបំពេញបានសមរម្យសម្រាប់ពេលវេលា ដែលមាននៅចំពោះ មុនពេលនៅក្នុងអំឡុងពេល និងក្រោយពេលសវនាការនោះទេ ។

ជាទីបញ្ចប់ អង្គជំនុំជម្រះសាលាដំបូង ក៏ធ្វើការកត់សម្គាល់ផងដែរនូវបញ្ហា ដែលបានលើកឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងលក្ខខណ្ឌការងារកង្វះថវិកាឧបត្ថម្ភ និងភាព ដែលអាចចូលរួមបានរបស់មេធាវីមួយចំនួន ពីខែសីហា ឆ្នាំ២០០៩ ។

តំណាងនៃការិយាល័យរដ្ឋបាល ដែលបានចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការ បានធ្វើការកត់សម្គាល់ទៅលើសំណើទាំងពីរខាងលើនេះ ដែលបញ្ហានេះអង្គជំនុំជម្រះយល់ថា មិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលត្រូវដោះស្រាយនោះទេ ។ ទាក់ទងទៅនឹងសំណើទីបី គឺភាពដែលអាចចូលរួមបានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ពីខែសីហា ឆ្នាំ២០០៩ នោះ អង្គជំនុំជម្រះ នឹងធ្វើទំនាក់ទំនងជាមួយអង្គភាពជនរងគ្រោះ ដើម្បីធានាថាអវត្តមានណាមួយ របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមិនបង្កឲ្យមានការអាក់ខាន ដល់ដំណើរការសវនាការនោះឡើយ ។

**ការតាំងសំនួរដល់ជនជាប់ចោទទាក់ទងនិងប្រតិបត្តិការ ស ២១ និង ជើង ឯក**

- អង្គជំនុំជម្រះតាំងសំនួរដល់ជនជាប់ចោទទាក់ទងនិងប្រតិបត្តិការ ស ២១ ជាពិសេសទាក់ទងនិង៖
  - ការចាប់ខ្លួនបុគ្គលសំខាន់ៗ
  - ការបែងចែកបន្ទប់ឃុំឃាំង និង ស្ថានភាពអ្នកជាប់ឃុំក្នុងបន្ទប់ឃុំឃាំង រួមបញ្ចូលទាំងជនបរទេស ស្ត្រី និងកុមារ

<u>អង្គជំនុំជម្រះផ្អាកនូវការសួរចំលើយ ហើយនឹងបន្តសួរនៅថ្ងៃទី នៅថ្ងៃទី ១៦ មិថុនា ២០០៩</u>។

**ការទទួលយកសំណើររបស់លោក មេធាវី** Pierre Olivier Sur **ដែលសុំ ឲ្យជំនួយការរបស់គាត់**



E.C.C.C. TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

00363516



**Jessica Finelle បានចូលរួមសវនការ**

- អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចរបស់ខ្លួន ដែលអនុញ្ញាតឲ្យទីប្រឹក្សាផ្នែកច្បាប់ ក្រុម ៤ ឈ្មោះ Jessica Finelle បានចូលរួមសវនាការក្នុងនាមលោក Pierre Olivier Sur ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោង របស់អជសដ | លេខយោងរបស់ កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត សំងាត់ ឬសាធារណ:) | កំណត់សម្គាល់ |
|---|---|---|---|---|
| E3/230 | D57 | សំណើរសុំរបស់សហព្រះរាជអាជ្ញា សុំឲ្យដាក់បញ្ចូលបញ្ជីអ្នកទោស ស២១ ដែលទាក់ទងដល់ការបង្ហាញពីចំនួននិងប្រភេទជនរងគ្រោះ ដែលត្រូវបានសម្លាប់នៅមន្ទីសន្តិសុខ ស ២១ | សាធារណ: | 00172366-00172367 |
| E3/231 | ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ 14.3 | កំណត់ហេតុរបស់ ម៉ម ណៃ ហៅ ចាន់ | សាធារណ: | 00077661-00078056, 00184579-00184618, |
| E3/229 | D69 ឧបសម្ព័ន្ធ ក | ខ្សែភាពយន្តឯកសាររបស់ប្រទេសវៀតណាមដែលនិយាយអំពីការរកឃើញមន្ទីរ ស ២១ (វគ្គ២) | សាធារណ: | V00172621 មាននៅក្នុង E3 folder រួចហើយ |
| E3/232 | D45/1/2 | រូបថតជាច្រើនដែលបានដាក់បង្ហាញ ជាពិសេសពីរូបថតទី ៣៩ ទៅ ៥០ | សាធារណ: | 00195373-00195377, 00189128-00189130 [illegible] |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃនីតិវិធី- ១៥ មិថុនា ២០០៩ /សាធារណ:

| | | | | |
|---|---|---|---|---|
| E52/4.62 | NA | ឧបសម្ព័ន្ធ ៦២ ឯកសារដែលមានឈ្មោះជនបរទេសដែលត្រូវបានគេឃុំខ្លួន ឬត្រូវបានគេសម្លាប់ ដោយខ្មែរក្រហម នៅ ស ២១ | សាធារណៈ | 00320844-00320845 |
| E68.8 | NA | ភាគរយនៃបុរស ស្ត្រីនិងកុមារនៅ ស ២១ | សាធារណៈ | 00331261 |
| E68.7 | NA | ឧបសម្ព័ន្ធ ៧ អ្នកទោសជាប់នៅ ស ២១ ដែលបង្ហាញថាជាកុមារ | សាធារណៈ | 00331257-00331260 |
| E3/333 | D42/1/4 | កំណត់សំគាល់សរសេរដោយដៃរបស់ ឌុច ដែលបញ្ជាក់លើឯកសារ ERN 00006728 | សាធារណៈ | 00197738-00197738 |
| E68.6 | NA | ឧបសម្ព័ន្ធ ៦ អ្នកទោសជាប់នៅស ២១ ដែលបង្ហាញថាជាស្ត្រី | សាធារណៈ | 00331192-00331256 |

<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>

- អង្គជំនុំជម្រះប្រកាសនូវផ្នែកនៃសេចក្តីសម្រេចលើសំណើរសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ

**អង្គជំនុំជម្រះសាលាដំបូង:**

**បដិសេធ** សំណើសុំដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំនេះ។

**បង្គាប់ថា** ជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនជាបន្តទៀត នៅក្នុងអំឡុងពេលសវនាការ។

**រកឃើញថា** ការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធាគឺមានកំហុសក្នុងការអនុវត្តច្បាប់នីតិវិធី រំលោភលើសិទ្ធិរបស់ជនជាប់ចោទ ដូច្នេះហើយ ការឃុំខ្លួននេះមិនត្រឹមត្រូវតាមច្បាប់ទេ។

**ប្រកាសថា** ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់តុលាការយោធា និងចំពោះការរំលោភលើសិទ្ធិរបស់គាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងតាមច្បាប់អន្តរជាតិទូទៅ។

**កត់សម្គាល់ថា** ប្រសិនបើត្រូវបានសម្រេចឲ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់នោះ ជនជាប់ចោទអាចទាមទារសំណងសមស្របចំពោះរយៈពេល ដែលត្រូវបានឃុំខ្លួននៅតុលាការយោធា និងចំពោះការរំលោភសិទ្ធិរបស់គាត់នៅតុលាការជាតិ។

**ប្រកាសថា** ប្រសិនបើរកឃើញថាមានពិរុទ្ធភាព នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេល ដែលត្រូវបានឃុំខ្លួនក្រោមសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺចាប់តាំងពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ដោយអនុវត្តតាមមាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រកាសបន្ថែមថា** ប្រសិនបើរកឃើញថាមានពិរុទ្ធភាព នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការទូទាត់ចំពោះរយៈពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួន ក្រោមសមត្ថកិច្ចរបស់តុលាការយោធា គឺចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ ។

**ពន្យារនូវការសម្រេច** លើបញ្ហានៃចរិតលក្ខណៈនិងទំហំនៃសំណងបន្ថែម ដែលជាបច្ច័យនៃការរំលោភលើសិទ្ធិរបស់ជនជាប់ចោទដល់អង្គជំនុំជម្រះ ដើម្បីពិចារណានៅពេលធ្វើការសម្រេចសេចក្តីអំពីទោស ប្រសិនត្រូវយកមកពិចារណា។

- បង្គាប់ឲ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៩ ។

| ដីកាសម្រាប់ការលើកពេលសវនាការ |
| --- |
| • សវនាការនឹងបន្តទៅថ្ងៃអង្គារ ទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ៩.00 ព្រឹក ។ |

ភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩

ក្រឡាបញ្ជី

ឌុច ផារី ... ELS-RISER

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE
E.C.C.C.